# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ 003/04 គ.ជ.ប

## សេចក្ដីសម្រេច

### ស្ដីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ គណបក្ស ប្រជាជនកម្ពុជា ចេញពីមណ្ឌលខេត្ត កំពង់ចាម

---

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម នស/រកម/១២៩៧.០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីការប្រកាសឱ្យប្រើច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម ជស/រកម/១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០២/៣០០ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០២ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៣ ។
- បានឃើញសេចក្ដីសម្រេចលេខ ០៥.២៣២/០៣ គ.ជ.ប. ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។
- បានឃើញសេចក្ដីសម្រេចលេខ ០៨.៥១៧/០៣ គ.ជ.ប. ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣ ស្ដីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិ ទី ៣ ។
- បានឃើញលិខិតលេខ ៨៨៨ លគ.គក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៤ ស្ដីពីការសុំប្រកាសទទួលស្គាល់បេក្ខជនជាប់ឆ្នោតថ្មីរបស់គណបក្ស **ប្រជាជនកម្ពុជា** ។

## សម្រេច

**ប្រការ១** : លុបឈ្មោះឯកឧត្ដម **ម៉ាត់ លី** ភេទ ប្រុស អាយុ ៧៣ ឆ្នាំ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ គណបក្ស **ប្រជាជនកម្ពុជា** ចេញពីបញ្ជីបេក្ខជនឈរឈ្មោះនៅមណ្ឌលខេត្ត **កំពង់ចាម** ដែលបានទទួលមរណភាពកាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៤ ។

**ប្រការ២** : គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ៣** : សេចក្ដីសម្រេចនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី23 ខែ មីនា ឆ្នាំ ២០០៤

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម សួស្ដី

**ចម្លងជូនថ្វាយ**
- ព្រះមហាក្សត្រ

**ចម្លងជូន**
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- មជ្ឈមណ្ឌលតំកល់ឯកសារជាតិ
- គណបក្សនយោបាយ "ដើម្បីជូនជ្រាប"
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ